## ៣- សេចក្តីប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០០

### សេចក្តីប្រកាសលេខ ០១ សប្រក.

### ស្តីពីវិធានការចាត់តាំងអនុវត្តផែនការជាតិ ៥ឆ្នាំ ប្រឆាំងការជួញដូរ និង កេងប្រវ័ញ្ចផ្លូវភេទលើកុមារ

***

ដោយពិនិត្យឃើញថា ចាប់តាំងពីពេលមានច្បាប់ស្តីអំពីការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើធ្វើ អាជីវកម្មលើមនុស្ស ដែលចូលជាធរមាននៅ ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ១៩៩៦ ក្រសួង-ស្ថាប័ន មានសមត្ថកិច្ចបានអនុវត្ត វិធានការជាបន្តបន្ទាប់ ដើម្បីទប់ស្កាត់និងបង្ក្រាបអំពើចាប់ពង្រត់ជួញដូរផ្លូវភេទ ប៉ុន្តែសកម្មភាពនេះនៅតែកើតមាននៅឡើយក្នុងសង្គមជាតិ ហើយកុមារគឺជាមុខសញ្ញាចម្បងសំរាប់ការជួញដូរផ្លូវភេទ ។

ក្រុមជនទុច្ចរិតបានប្រព្រឹត្តអំពើបោកប្រាស់កុមារតាមគ្រប់រូបភាព ដូចជាការប្រើល្បិចល្បួងលោម អូសទាញទឹកចិត្ត ការបង្ខិតបង្ខំគំរាមកំហែង ការប្រើប្រាស់ថ្នាំដែលមានគការធាតុញៀនជាដើម ។ ទន្ទឹមនេះដែរមានករណីក្រុមជនទុច្ចរិត បានរៀបចំជាប្រព័ន្ធ មានខ្សែបណ្តាញចាប់ពង្រត់ ជួញដូរផ្លូវភេទលើកុមារឆ្លងដែនជាពិសេសជាមួយប្រទេសជិតខាង ។

សកម្មភាពល្មើសច្បាប់ អមនុស្សធម៌ ធ្វើឲ្យមានការប៉ះពាល់យ៉ាងខ្លាំងដល់តម្លៃមនុស្សជាតិ ដល់វប្បធម៌ ទំនៀមទំលាប់ប្រពៃណីជាតិ ជាការរំលោភដល់សិទ្ធិកុមារ រំលោភសិទ្ធិមនុស្សដែលមិនអាចអត់អោនបាន-។

យោងតាមគំរោងផែនការនៃសន្និសីទជាតិ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ដែលបានប្រព្រឹត្តទៅនៅថ្ងៃ ទី៦-៧ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីផែនការជាតិ៥ឆ្នាំប្រឆាំងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ។ ក្នុងទិសដៅ :

- ទប់ស្កាត់អំពើជួញដូរ និង កេងប្រវ័ញ្ចផ្លូវភេទលើកុមារ
- បង្កើនប្រសិទ្ធភាពក្នុងការអនុវត្តន៍ :
  + រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីសិទ្ធិកុមារដែលមានចែងក្នុងមាត្រា៣១-៤៦-៨៥ ។
  + ច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និង អំពើធ្វើអាជីវកម្មលើមនុស្ស។
  + អនុសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិកុមារ ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ននៅឆ្នាំ១៩៩២។
  + អនុសញ្ញាស្តីអំពីអាយុអប្បបរមារបស់កុមារ អាចចូលធ្វើការបានលេខ ១៣៨ ដែល ព្រះរាជាណាចក្រកម្ពុជា បានផ្តល់សច្ចាប័ននៅថ្ងៃទី១៩ កក្កដា ១៩៩៩ ។

+ សេចក្តីប្រកាស និង កម្មវិធីសកម្មភាពសកល នាទីក្រុងស្តុកខុលម៍ ឆ្នាំ១៩៩៦។

**- រាជរដ្ឋាភិបាលចេញសេចក្តីប្រកាសដូចតទៅ :**

ក)- ទទួលយកផែនការជាតិ ៥ឆ្នាំ ស្តីពីការប្រឆាំងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទ លើកុមារកាលពីថ្ងៃទី៦-៧ ខែកក្កដា ឆ្នាំ ១៩៩៩ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារធ្វើជាផែនការជាតិ៥ឆ្នាំ របស់រាជ រដ្ឋាភិបាល។

ខ)- ប្រគល់ភារកិច្ចដល់ក្រសួង-ស្ថាប័ន អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ សហគមន៍ទាំងមូលដើម្បីឲ្យផែន ការជាតិនេះត្រូវបានអនុវត្ត ដោយពិតប្រាកដដូចតទៅ :

**១- ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងយុត្តិធម៌**

- ពិនិត្យឡើងវិញនូវច្បាប់ដែលពាក់ព័ន្ធជាមួយកុមារ និង រៀបចំបំពេញបន្ថែមនូវលិខិតបទដ្ឋាននានាជាចាំបាច់ ដើម្បីការពារសិទ្ធិរបស់កុមារ ។

- ពិនិត្យ និង រៀបចំបំពេញបន្ថែមនូវលិខិតបទដ្ឋាននានាជាចាំបាច់ ក្នុងការអនុវត្តន៍ច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស ។

- ចាត់វិធានការម៉ឺងម៉ាត់បង្ក្រាបជនទុច្ចរិត ដែលប្រកបរបររកស៊ីជួញដូរកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមគ្រប់រូបភាព ។

- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាង និងប្រទេសក្នុងតំបន់ ដើម្បីមានវិធានការរួមគ្នាប្រឆាំងការជួញដូរកុមារឆ្លងដែន ។

- ពង្រឹងការត្រួតពិនិត្យ បណ្តាច្រករបៀងចេញចូលប្រទេសជិតខាងឲ្យបានតឹងរ៉ឹងមិន ឲ្យមានការនាំចេញ-នាំចូលនូវកុមារក្នុងគោលបំណងបំរើពលកម្ម ឬ ការជួញដូរផ្លូវភេទ ។

- ត្រួតពិនិត្យយ៉ាងតឹងរ៉ឹងនូវការដាក់លក់ និង ផ្សព្វផ្សាយរូបភាពអាសអាភាស ការនាំចូលនូវថ្នាំសំរើបថ្នាំ មានសារធាតុញៀន ដែលអាចបំពុលសតិអារម្មណ៍ និងធ្វើឲ្យខូចសុខភាព ពិសេសកុមារ និងយុវវ័យ កម្ពុជា ។

**២- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងព័ត៌មាន ក្រសួងទេសចរណ៍**

- ផលិតសំភារៈ ឯកសារ បំរើការផ្សព្វផ្សាយ និង រៀបចំកម្មវិធីផ្សព្វផ្សាយដ៏មានប្រសិទ្ធភាពតាមប្រព័ន្ធផ្សព្វផ្សាយចំរុះ ឲ្យមានការយល់ដឹងជាសាធារណៈ ពិសេសដល់កុមារ យុវវ័យ និងក្រុមគ្រួសារអំពីសិទ្ធិ ជាមួយលដ្ឋានច្បាប់ផ្សេងៗពាក់ព័ន្ធទៅនឹងកុមារ ។

- ណែនាំដល់អង្គភាពផលិតកម្មវិធីសិល្បៈគ្រប់ប្រភេទ ឲ្យធ្វើការបញ្ចូលខ្លឹមសារ ស្តីពីសិទ្ធិជាមូលដ្ឋានរបស់កុមារ ការទប់ស្កាត់អំពើជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទទៅលើកុមារ ។

- រៀបចំកម្មវិធីអប់រំតាមរយៈសិល្បៈ និងទស្សនីយភាពដូចជាល្ខោនខ្លីៗ ក្នុងសិល្បៈសម័យ និងបុរាណល្បែងកំសាន្តនានានាទីភាពយន្ត ដែលមានខ្លឹមសារផ្សារភ្ជាប់ការលើកស្ទួយសិទ្ធិរបស់កុមារ និង ទប់ស្កាត់ការជួញដូរកេងប្រវ័ញ្ចផ្លូវភេទទៅលើកុមារ ។

- ចែកចាយសម្ភារៈផ្សព្វផ្សាយ និង ធ្វើការណែនាំដល់ភ្នាក់ងារទេសចរណ៍ ម្ចាស់សណ្ឋាគារ ភោជនីយដ្ឋាន ព្រលានយន្តហោះជាតិ អន្តរជាតិ ឲ្យយល់ដឹងអំពីច្បាប់ និង វិធានការទប់ស្កាត់ បាតុភាពអសកម្មទាំងអស់នោះ ។

**៣- ក្រសួងធម្មការ និង កិច្ចការសាសនា ក្រសួងអប់រំ យុវជន និងកីឡា**

- បំផុសព្រះសង្ឃ ដូនជី និង អាចារ្យ ឲ្យចូលរួមក្នុងចលនាឃោសនាអំពីសិទ្ធិរបស់កុមារ និង ផ្តល់សេវាចិត្តសាស្ត្រដល់ជនរងគ្រោះ ។

- បញ្ចូលទៅក្នុងកម្មវិធីសិក្សា នូវប្រធានបទស្តីអំពីសិទ្ធិរបស់កុមារ ការអប់រំផ្លូវភេទ ការជួញដូរកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងមានវិធានការហ្មឺងម៉ាត់ ពង្រឹងវិន័យសីលធម៌ទប់ស្កាត់ការបង្កើតក្រុមបងធំ ការប្រើសារធាតុញៀននៅតាមសាលារៀន ។

- ធ្វើអោយប្រជាពលរដ្ឋមានការយល់ដឹងអំពីច្បាប់ពាក់ព័ន្ធទៅនឹងកុមារ ជាពិសេសច្បាប់ស្តីពីការបង្ក្រាប អំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស ។

**៤- ក្រសួងកិច្ចការនារី និង អតីតយុទ្ធជន ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ក្រសួង សុខាភិបាល និងក្រសួងអភិវឌ្ឍន៍ជនបទ**

- ធ្វើការបំផុសចលនាចូលរួមរបស់សហគមន៍ ដើម្បីត្រួតពិនិត្យតាមដាន និងរកវិធីទប់ស្កាត់កុមារកុំឲ្យបង់ខ្លួនក្នុងអំពើពេស្យាកម្ម និងជួយធ្វើអន្តរាគមន៍សង្គ្រោះកុមារទាន់ពេលវេលា ឬធ្វើការកសាងសំណុំរឿង បណ្តឹងតុលាការ ដើម្បីចោទប្រកាន់ជនល្មើស និងអ្នករួមគំនិត ។

- បង្កើនសេវាពិនិត្យ និងព្យាបាលសុខភាពដោយឥតគិតថ្លៃ និង ផ្តល់ប្រឹក្សាយោបល់វេជ្ជសាស្ត្រដល់តុលាការ អំពីភាពរងគ្រោះរបស់កុមារ ។

- មានវិធានការទប់ស្កាត់ពេស្យាចារកុមារ តាមរយៈការត្រួតពិនិត្យ ការគ្រប់គ្រង និង ការប្រើប្រាស់ពលកម្ម ជាពិសេសការប្រើប្រាស់កុមារ រនៅតាមសេវាទេសចរណ៍និង សេវាបំរើការកំសាន្តគ្រប់រូបភាព ។

- បង្កើនសេវាជួយរំដោះ និង គាំទ្រជនរងគ្រោះដែលត្រូវបានរំដោះចេញអំពីផ្ទះបនឬកន្លែងបង្ខាំងទុកនានា អោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ហើយធ្វើការអប់រំ ថែបំប៉នសុខភាព និង បណ្តុះ បណ្តាលជំនាញ ដើម្បីកែប្រែមុខរបរ ។

- រៀបចំផែនការសកម្មភាព លើកកំពស់ជីវភាពគ្រួសារតាមសហគមន៍ កាត់បន្ថយភាពក្រីក្រ ក្នុងគ្រួសារ និងជួយរកការងារឲ្យកុមារធ្វើ ស្របទៅតាមបទដ្ឋានការងារជាធរមាន ។

៥- គ្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

- បង្កើតយន្តការថ្នាក់ជាតិដែលមានក្រសួង-ស្ថាប័ន មានសមត្ថកិច្ចចូលរួម និងថ្នាក់ខេត្ត-ក្រុង ដើម្បីតាមដានការអនុវត្តន៍ផែនការជាតិ៥ឆ្នាំនេះ ហើយមានភារកិច្ចរាយការណ៍ ជាប្រចាំជូនរាជរដ្ឋាភិបាលអំពីលទ្ធផល នៃការអនុវត្តន៍ផែនការជាតិនេះ ។

៦- រាជរដ្ឋាភិបាលសូមអំពាវនាវដល់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ចូរចៀសវាងដាច់ខាតកុំចូលពាក់ពន្ធ័ ឬធ្វើខ្នងបង្អែក ឲ្យជនទុច្ចរិតប្រកបរបរជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ។ ជនណាដែលប្រព្រឹត្តល្មើស នឹងត្រូវ ផ្តន្ទាទោសតាមច្បាប់ ។

៧- រាជរដ្ឋាភិបាលសូមអំពាវនាវដល់មាតាបិតា អាណាព្យាបាល ត្រូវយកចិត្តទុកដាក់ ពិនិត្យតាមដានឲ្យបានដិតដល់នូវរាល់សកម្មភាពរបស់បុត្រធីតាខ្លួន ហើយធ្វើការអប់រំណែនាំជាប្រចាំ ដើម្បីកុំឲ្យកុមារធ្លាក់ក្នុងអំពើអបាយមុខផ្សេងៗ ដែលងាយដល់ជនទុច្ចរិតអូសទាញ ប្រើប្រាស់ប៉ះពាល់គោលដៅឧក្រិដ្ឋកម្មរបស់គេ ។

៨- រាជរដ្ឋាភិបាលសូមអំពាវនាវដល់បណ្តាអង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ដែលកំពុងបំពេញភារៈកិច្ចដើម្បីបុព្វហេតុសិទ្ធិជាមូលដ្ឋាននៃកុមារ និងកិច្ចអភិវឌ្ឍន៍ផ្លូវកាយ ផ្លូវចិត្តដល់កុមារ សូមឲ្យបង្កើនសកម្មភាពរបស់ខ្លួន បន្ថែមទៀត ដើម្បីគាំទ្រដល់ផែនការជាតិ ៥ឆ្នាំនេះ ។

ទទួលបានសេចក្តីប្រកាសនេះក្រសួង-ស្ថាប័ន អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវធ្វើការផ្សព្វផ្សាយ និង អនុវត្តផែនការជាតិ៥ឆ្នាំប្រឆាំងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ហើយត្រូវចាត់តាំងធ្វើផែនការអនុវត្ត ជាក់ស្តែងឲ្យស្របតាមស្ថាប័ននីមួយៗ រួចរាយការណ៍អំពីលទ្ធផលតាមដំណាក់កាលៗ មកក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ដើម្បីបូកសរុបរបាយការណ៍ជូនរាជរដ្ឋាភិបាល ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***